ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

**សំណុំរឿង**

លេខ : ៣៨៥/០៨៣/២០១៧

ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧

**សេចក្តីសម្រេច**

លេខ : ១៨៨/០២៨/២០១៧ កបធ.ច

ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៧

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុម-ប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ០៨៨/០៨១៧/ពស/នវ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧ របស់ឯកឧត្តម **ឆៃ ម៉េណា** ប្រធានស្តីទីព្រឹទ្ធសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ដែលព្រឹទ្ធសភាបានអនុម័តយល់ព្រមចំនួន ៤៣ សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧ នាសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី៣ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលលិខិតខាងលើនេះនៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧ វេលាម៉ោង ១៦:០០